**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ខុទ្ទកាល័យ
ចូល
លេខ 1802
ថ្ងៃទី 03-7-012 ម៉ោង 16 30
បញ្ជូន

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ ៦៨៤ សជណ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជំរាបជូន**

**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍សម្រាប់ការកំណត់ទំហំដីដែលបានដាំដុះជាក់ស្តែង និងត្រូវធ្វើប្រទានកម្មជូនប្រជាពលរដ្ឋជាកម្មសិទ្ធិ ។

**យោង ៖** -លិខិតលេខ ៧៧០ ដនស/កករ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ ចំពោះករណីសំណើសុំគោលការណ៍សម្រាប់ការកំណត់ទំហំដីដែលបានដាំដុះជាក់ស្តែង និងត្រូវធ្វើប្រទានកម្មជូនប្រជាពលរដ្ឋជាកម្មសិទ្ធិ នោះ រាជរដ្ឋាភិបាលបានយល់ព្រមតាមសំណើដូចខាងក្រោម ៖

១-អ្នកកាន់កាប់ដីលើសពី ០៥ហិកតា ទោះមានទីលំនៅឬមិនមានទីលំនៅលើទីតាំងដីដែលបានដាំដុះជាក់ស្តែង ត្រូវធ្វើប្រទានកម្មជូនគាត់ជាកម្មសិទ្ធិមិនលើសពីទំហំ២០០(ពីររយ)ហិកតា។

២- ចំពោះដីដែលត្រូវផ្តល់ជាសម្បទានសេដ្ឋកិច្ចខ្នាតតូច ចំណូលពីថ្លៃសម្បទានដីសេដ្ឋកិច្ចខ្នាតតូច នឹងត្រូវកំណត់និងបែងចែកសម្រាប់ជាប្រភពចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលអាជ្ញាធរចុះកិច្ចសន្យា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីស្តីទី**

**ប្រាក់ សុខុន**

**ចំលងជូន ៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ